ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ៣៣ អយក.សណន

# សេចក្តីណែនាំ
## ស្តីពី
## ការបន្តការអនុវត្តកម្មវិធីសិក្សាពីប្រធានបទអប់រំសុខភាព នៅតាមគ្រឹះស្ថានបឋមសិក្សា មធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស

**យោង ៖** - អនុក្រឹត្យលេខ២៥ អនក្រ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ ស្តីពីអនាម័យសិក្សា
- គោលនយោបាយ ស្តីពីសុខភាពសិក្សា
- ប្រកាសលេខ៥៧ អយក.ប្រក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៦ ស្តីពីកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស ។

ក្រសួងអប់រំ យុវជន និងកីឡានឹងបញ្ចូលមុខវិជ្ជាអប់រំសុខភាពក្នុងកម្មវិធីសិក្សាចំណេះទូទៅចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី១២ ដើម្បីផ្តល់ឱកាសដល់សិស្សបានសិក្សាពីការអប់រំសុខភាពនៅតាមគ្រឹះស្ថានសិក្សានាឆ្នាំសិក្សា២០១៩ខាងមុខ។ នាអំឡុងពេលនៃការអភិវឌ្ឍមុខវិជ្ជាអប់រំសុខភាពឆ្នាំ២០១៦-២០១៨ និងក្នុងគោលបំណងបន្ត និងជំរុញការអនុវត្តកម្មវិធីសិក្សាលើប្រធានបទអប់រំសុខភាព នៅតាមគ្រឹះស្ថានសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស ឱ្យមានដំណើរការល្អដូចមានចែងក្នុងខ្លឹមសារនៃឯកសារគតិយុត្តខាងលើ ក្រសួងសូមធ្វើការណែនាំដល់គ្រប់មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ត្រូវធ្វើការណែនាំបន្តដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡា ខណ្ឌ ក្រុង ស្រុក និងគ្រប់គ្រឹះស្ថានសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេសដូចខាងក្រោម ៖

### ក. សម្រាប់គ្រឹះស្ថានបឋមសិក្សា
#### ១- ការប្រើប្រាស់ម៉ោងសិក្សា

- ត្រូវដាក់បញ្ចូលខ្លឹមសារមេរៀន ដែលធ្លាប់ទទួលបានការបំប៉ន ឬបណ្តុះបណ្តាលកន្លងមកទៅតាមកម្រិតថ្នាក់ដូចបានកំណត់នៅក្នុងមេរៀននីមួយៗ ទៅក្នុងផែនការ និងកាលវិភាគបង្រៀនប្រចាំឆ្នាំសិក្សា ដោយកំណត់ ១ម៉ោងសិក្សា ក្នុង ១សប្តាហ៍។



អាសយដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ៤២៧ ៣៩៦ / ២១៧ ២៥៣ / ៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣)២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

- ការបង្រៀនមុខវិជ្ជាអប់រំសុខភាពនេះ ត្រូវធ្វើពេញមួយឆ្នាំសិក្សា ជារៀងរាល់ឆ្នាំរហូតដល់មានការណែនាំថ្មី ។

**២- ខ្លឹមសារមេរៀនអប់រំសុខភាព**

ខ្លឹមសារមេរៀន "អប់រំសុខភាព" អាចធ្វើការជ្រើសរើសដូចជា ៖

- ការអប់រំបង្ការជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម ជំងឺរាក ជំងឺផ្តាសាយ របេង និងដង្កូវព្រូន
- ការអប់រំពីសារប្រយោជន៍នៃការចាក់ថ្នាំបង្ការជំងឺនានា
- ការអប់រំពីគ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់គ្រឿងញៀន គ្រឿងស្រវឹង
- ការអប់រំពីសុខភាពភ្នែក សុវត្ថិភាពចំណីអាហារ អាហារូបត្ថម្ភ និងអនាម័យ
- ការអប់រំបំណិនជីវិត ស្តីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ
- ការអប់រំពីប្រធានបទសុខភាពចាំបាច់ផ្សេងទៀត ដែលកើតមានញឹកញាប់នៅតាមមូលដ្ឋានសាលារៀន។

**៣- ការប្រើប្រាស់ធនធានគ្រូបង្រៀន**

- ត្រូវចាត់តាំងគ្រូប្រចាំថ្នាក់ជាអ្នកបង្រៀនមុខវិជ្ជា "អប់រំសុខភាព" នេះដូចមុខវិជ្ជាដទៃទៀតដែរ
- នាយក នាយិកា លោកគ្រូ អ្នកគ្រូ ត្រូវដឹកនាំការបង្រៀនមុខវិជ្ជាអប់រំសុខភាព ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តជាក់ស្តែង តាមភូមិសាស្ត្រ នៃគ្រឹះស្ថានសិក្សានីមួយៗ ដូចជា ការរៀបចំវិធានអនាម័យ ការគ្រប់គ្រងសំរាម ឬកាកសំណល់រឹង រាវ ការលាងសម្អាតដៃក្រោយចេញពីបង្គន់ ឬមុនពេលចាប់កាន់ចំណីអាហារញ៉ាំ ការដុសសម្អាតធ្មេញ ការត្រួតពិនិត្យអនាម័យខ្លួនប្រាណសិស្សានុសិស្ស។ល។

**៤- ការកំណត់ដាក់ពិន្ទុ**

- ការបង្រៀនមុខវិជ្ជា "អប់រំសុខភាព" ត្រូវកំណត់ដាក់ពិន្ទុ និងវាយតម្លៃប្រចាំខែ ត្រីមាស ឬឆមាស ដូចមុខវិជ្ជាដទៃទៀតដែរ
- ត្រូវលើកទឹកចិត្តសិស្សានុសិស្ស ដែលអនុវត្តបានល្អនូវការរក្សាអនាម័យ និងវិធានការលើកកម្ពស់សុខភាពនៅតាមគ្រឹះស្ថានសិក្សា ដោយចេញជាប័ណ្ណ ឬលិខិតសរសើរ ឬការផ្តល់ជាកិត្តិយសក្នុងពិធីផ្លូវការនានា។ល។

## ខ. សម្រាប់គ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស

**១- ការប្រើប្រាស់ម៉ោងសិក្សា**

- ត្រូវដាក់បញ្ចូលខ្លឹមសារមេរៀន ដែលធ្លាប់ទទួលបានការបំប៉ន ឬបណ្តុះបណ្តាលកន្លងមកទៅតាមកម្រិតថ្នាក់ ដូចបានកំណត់នៅក្នុងមេរៀននីមួយៗ ទៅក្នុងផែនការ

និងកាលវិភាគបង្រៀនប្រចាំឆ្នាំសិក្សា ដោយកំណត់ ១ម៉ោងសិក្សា ក្នុង ១សប្ដាហ៍ នៃម៉ោងអប់រំបំណិនជីវិតតាមមូលដ្ឋានដែលមាន ២ ទៅ ៥ម៉ោងក្នុង ១សប្ដាហ៍ សម្រាប់ថ្នាក់ទី៧ ដល់ទី១០ និងក្នុងម៉ោងអប់រំវិជ្ជាជីវៈជម្រើស ដែលមាន ២ម៉ោងក្នុង ១សប្ដាហ៍ សម្រាប់ថ្នាក់ទី១១

- ការបង្រៀនមុខវិជ្ជាអប់រំសុខភាពនេះ ត្រូវធ្វើពេញមួយឆ្នាំសិក្សា ជារៀងរាល់ឆ្នាំរហូតដល់មានការណែនាំថ្មី ។

## ២- ខ្លឹមសារមេរៀនអប់រំសុខភាព

ខ្លឹមសារមេរៀន "អប់រំសុខភាព" អាចធ្វើការជ្រើសរើសដូចជា ៖

- ការអប់រំបង្ការជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម ជំងឺផ្ដាសាយ របេង និងជំងឺអេដស៍
- ការអប់រំបង្ការគ្រោះថ្នាក់ចរាចរណ៍ គ្រោះថ្នាក់នៃការប្រើគ្រឿងញៀន គ្រឿងស្រវឹង និងគ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំជក់
- ការអប់រំសុខភាពភ្នែក ការអប់រំអនាម័យ សុវត្ថិភាពចំណីអាហារ
- ការអប់រំបំណិនជីវិត ស្ដីពីសុខភាពបន្តពូជ និងសុខភាពផ្លូវភេទ
- ការអប់រំពីវិធានការសង្គ្រោះបឋម
- ការអប់រំពីវិធានការអនុវត្តពេលមានគ្រោះមហន្តរាយ
- ការអប់រំពីប្រធានបទសុខភាពចាំបាច់ផ្សេងទៀត ដែលកើតមានញឹកញាប់នៅតាមមូលដ្ឋានសាលារៀន។

## ៣- ការប្រើប្រាស់ធនធានគ្រូបង្រៀន

- ត្រូវចាត់តាំងគ្រូទទួលបន្ទុកថ្នាក់ ឬគ្រូដែលធ្លាប់បានទទួលការបំប៉នពីប្រធានបទពាក់ព័ន្ធនឹងការអប់រំសុខភាពនាពេលកន្លងមក ឬគ្រូបង្រៀនមុខវិជ្ជាសីលធម៌ពលរដ្ឋ ភាសាខ្មែរ គេហវិទ្យា បរិស្ថាន ជីវវិទ្យា ជាអ្នកបង្រៀនមុខវិជ្ជា "អប់រំសុខភាព" ដូចមុខវិជ្ជាដទៃទៀតដែរ
- នាយក នាយិកា លោកគ្រូ អ្នកគ្រូ ត្រូវដឹកនាំការបង្រៀនមុខវិជ្ជាអប់រំសុខភាព ដោយផ្សារភ្ជាប់ទៅនឹងការអនុវត្តជាក់ស្ដែង តាមភូមិសាស្ត្រ នៃគ្រឹះស្ថានសិក្សានីមួយៗ ដូចជា ការរៀបចំវិធានការអនាម័យ ការគ្រប់គ្រងសំរាម ឬកាកសំណល់រឹង រាវ ការលាងសម្អាតដៃក្រោយចេញពីបង្គន់ ឬមុនពេលចាប់កាន់ចំណីអាហារញ៉ាំ ការត្រួតពិនិត្យអនាម័យខ្លួនប្រាណសិស្សានុសិស្ស។ល។

## ៤- ការកំណត់ដាក់ពិន្ទុ

- ការបង្រៀនមុខវិជ្ជាអប់រំសុខភាព ត្រូវកំណត់ដាក់ពិន្ទុ និងវាយតម្លៃប្រចាំខែ ត្រីមាស ឬឆមាស ក្នុងមុខវិជ្ជាបំណិនជីវិតតាមមូលដ្ឋាន ឬកម្មវិធីអប់រំវិជ្ជាជីវៈជម្រើស

- ត្រូវលើកទឹកចិត្តសិស្សានុសិស្ស ដែលអនុវត្តបានល្អនូវការរក្សាអនាម័យ និងវិធានការលើកកម្ពស់សុខភាពនៅតាមគ្រឹះស្ថានសិក្សា ដោយចេញជាប័ណ្ណសរសើរ ឬលិខិតសរសើរ ឬការផ្តល់ជាកិត្តិយសក្នុងពិធីផ្លូវការនានាតាមគ្រឹះស្ថានសិក្សា។ល។

មន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត ការិយាល័យអប់រំ យុវជន និងកីឡា ខណ្ឌ ក្រុង ស្រុក ត្រូវពង្រឹង និងចូលរួមអនុវត្តកម្មវិធីលើកកម្ពស់សុខភាព ដោយបញ្ចូលទៅក្នុងការពិនិត្យតាមដានជាប្រចាំតាមសមត្ថកិច្ចរបស់ខ្លួន។

គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា និងក្រុមបច្ចេកទេស ត្រូវពិនិត្យតាមដាន និងវាយតម្លៃជាប្រចាំលើគ្រប់សកម្មភាពបង្រៀន និងរៀនរបស់លោកគ្រូ អ្នកគ្រូ នៅក្នុងសាលារៀនរបស់ខ្លួនដោយស្មារតីទទួលខុសត្រូវខ្ពស់។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត លោក លោកស្រីប្រធានការិយាល័យ អប់រំ យុវជន និងកីឡា ខណ្ឌ ក្រុង ស្រុក និងនាយក នាយិកាគ្រប់គ្រឹះស្ថានសិក្សាចំណោះទូទៅ និងអប់រំបច្ចេកទេស ចាត់ចែងអនុវត្តសេចក្តីណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**ចម្លងជូន**

- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- អង្គភាពពាក់ព័ន្ធក្រោមឱវាទ
  *"ដើម្បីជូនជ្រាបជាព័ត៌មាន"*
- មន្ទីរ អយក រាជធានី ខេត្ត *"ដើម្បីអនុវត្ត"*
- គ្រប់គ្រឹះស្ថានសិក្សា *"ដើម្បីអនុវត្ត"*
- ឯកសារ - កាលប្បវត្តិនសស